# សុន្ទរកថា

## ថ្លែងដោយសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ក្នុងព្រះរាជពិធីបុណ្យចម្រើន ព្រះជន្មថ្វាយព្រះមហាវីរក្សត្រ ក្នុងព្រះជន្មាយុ ៩០ព្រះវស្សា និងខួប ២០ឆ្នាំ នៃព្រះរាជដំណើរ យាងមាតុភូមិនិវត្តន៍របស់ សម្តេចឪ សម្តេចម៉ែ នៅទីលានមុខព្រះបរមរាជវាំង

## ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១១

- សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សូមក្រាបបង្គំទូលថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់
- សូមគោរព **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា និង **លោកជំទាវ**
- សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ ឯកឧត្តម លោកជំទាវ លោកឧញ៉ា អស់លោក លោកស្រី និង ជនរួមជាតិ ជាទីមេត្រី

ក្នុងឱកាសដ៏មហោឡារិកនេះ ទូលព្រះបង្គំជាខ្ញុំ ជំនួសមុខសម្តេចប្រធានសភាទាំងពីរ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកាព្រឹទ្ធសភា រដ្ឋសភា រាជរដ្ឋាភិបាល បណ្តាស្ថាប័នជាតិ អាជ្ញាធររាជធានី បណ្តាខេត្ត និងបងប្អូនជនរួមជាតិ ក្នុងទូទាំងព្រះរាជាណាចក្រកម្ពុជា សូមសំដែងនូវមនោសញ្ចេតនារំភើប រីករាយ ប្រកបដោយកតញ្ញូតាធមិដ៏ជ្រាលជ្រៅបំផុត ដែលបានមករួមគ្នាប្រារព្ធពិធីមិទ្ទិញមហាជននៅទីនេះ ដើម្បីឧទ្ទិស និង រំលឹកខួប ២០ឆ្នាំ នៃការយាងនិវត្តមកកាន់មាតុភូមិជាទីស្នេហារបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ដែលព្រះអង្គបានសព្វព្រះរាជហឫទ័យស្តេចយាងមកគង់ប្រថាប់ នៅជាកំពូលនៃការដឹកនាំ និងអនុវត្តគោលនយោបាយបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងកសាងប្រទេសជាតិឡើងវិញ។ គោរពតាមការប្រគល់ភារកិច្ចរបស់គណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាលនៃរដ្ឋកម្ពុជា ទូលព្រះបង្គំជាខ្ញុំ និងភរិយា ពិតជាមានកិត្តិយសដ៏ឧត្តុង្គឧត្តមណាស់ ដែលបានទៅយាងព្រះអង្គទាំងទ្វេ ពីសាធារណរដ្ឋប្រជាមានិតចិន បន្ទាប់ពីព្រះអង្គគង់នៅក្រៅប្រទេសអស់រយៈកាលច្រើនទសវត្សកន្លងមក ។

ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៩១ គឺជាថ្ងៃប្រវត្តិសាស្ត្ររបស់ប្រជាពលរដ្ឋខ្មែរ ដែលបានថ្វាយព្រះរាជបដិសណ្ឋារកិច្ចដ៏មហោឡារិកដោយក្តីនឹករលឹក រំភើបសោមនស្សរីករាយក្រៃលែង ដោយបានជួបជាថ្មីឡើងវិញ នូវ **ព្រះមហាក្សត្រ ព្រះមហាក្សត្រី** ជាទីគោរពស្រឡាញ់របស់ខ្លួន ដែលជាស្ថាបនិកដ៏ល្បីល្បាញ លេចឡើងឮរន្ទឺគ្រប់ទិសទីលើសកលលោក ក្នុងបុព្វហេតុនៃឯករាជ្យជាតិ និងសន្តិភាព ក្រោយដែលខានបានឃើញព្រះភក្ត្រដ៏ស្រស់ស្រាយ និងព្រះសូរសៀងដ៏ស្រទន់អស់រយៈកាលដ៏យូរឆ្នាំ។ នេះគឺជាទិដ្ឋភាពជាក់ស្តែង ដែលជាចំណុចចាប់ផ្តើមនៃការកកើតឡើងវិញ នៃ **ព្រះរាជាណាចក្រកម្ពុជាទី២**

**របស់មាតុភូមិអង្គរជាទីស្នេហារបស់យើង**។ ទូលព្រះបង្គំជាខ្ញុំទាំងអស់គ្នា ពិតជាមានមោទនភាពណាស់ ដោយមាន **ព្រះមហាក្សត្រ** ព្រះអង្គប្រកបដោយទសពិធរាជធម៌ ជាកំពូលអ្នកដឹកនាំប្រកបដោយព្រះបញ្ញាញាណភ្លឺថ្លា និងទេពកោសល្យ បានប្រទានក្តីសង្ឃឹម ក្នុងដំណើរកសាងសន្តិភាព ស្ថេរភាព ជីវភាពនយោបាយ សាមគ្គីភាពជាតិ ឯកភាពជាតិរឹងមាំ កសាងអភិវឌ្ឍន៏សង្គម និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ដោយសុខដុមរមនា ។

ទូលព្រះបង្គំជាខ្ញុំ និងភរិយា បានដង្ហែព្រះរាជដំណើរ **សម្តេចឪ សម្តេចម៉ែ** ព្រះអង្គយាងនិវត្តន៏មកកាន់មាតុប្រទេសវិញ ពីទីក្រុងប៉េកាំងរហូតដល់ទីក្រុងភ្នំពេញ។ ថ្នាក់ដឹកនាំគណបក្សប្រជាជនកម្ពុជា និងរដ្ឋភិបាលរដ្ឋកម្ពុជា បានបញ្ជាឱ្យមានការរៀបចំព្រះបរមរាជវាំងឡើងវិញ ដើម្បីថ្វាយព្រះអង្គទាំងទ្វេគង់ប្រថាប់តាមសព្វព្រះរាជហឫទ័យ។ នាថ្ងៃនោះ **ព្រះករុណាជាអម្ចាស់** និង **សម្តេចព្រះមហាក្សត្រី** ជាទីសក្ការៈ ស្តេចយាងមកដល់ទឹកដីជាទីស្នេហានៃយើង ទូលព្រះបង្គំជាខ្ញុំ និងភរិយា បានក្រាបបង្គំទូលថ្វាយនូវកូនសោរមាសមួយ ជាដួងព្រលឹងនៃប្រទេសជាតិ ថ្វាយព្រះអង្គក្នុងព្រះមហាប្រាសាទខេមរិន្ទ ជានិមិត្តរូប ដើម្បីព្រះអង្គគង់ជា **ព្រះមហាវីរក្សត្រជាតិខ្មែរ** ដឹកនាំកូនចៅទាំងអស់គ្នា ឆ្ពោះទៅរកសុខ សន្តិភាពតរៀងទៅ ។

កន្លងមកក៏ដូចបច្ចុប្បន្ន គណបក្សប្រជាជនកម្ពុជា និងរាជរដ្ឋាភិបាល ជានិច្ចកាលដង្ហែតាមព្រះរាជតម្រិះដ៏ថ្លៃថ្លាភ្លឺស្វាងរបស់ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ជារៀងរហូត និងតែងបានសំដែងថ្វាយនូវមនោសញ្ចេតនាគោរពស្រឡាញ់ ក្នុងទឹកចិត្តប្រកបដោយកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុត និងស្មោះត្រង់បំផុត ចំពោះព្រះអង្គ ជា **ព្រះបិតាឯករាជ្យជាតិ បូរណភាពទឹកដី និងផ្សះផ្សារជាតិ** ។

អង្គមហាមីទ្ទិញមហាជនថ្ងៃនេះ គឺជាការបង្ហាញរូបភាពជាក់ស្តែង នៃទឹកចិត្តប្រជារាស្ត្រ ជាកូនចៅ ចៅទួតរបស់ព្រះអង្គដែលជានិច្ចកាល តែងថ្វាយព្រះរាជសព្ទសាធុការពរ ចំពោះព្រះករុណាថ្លៃវិសេស តាមរយៈការបំពេញអាយុវឌ្ឍនមង្គល គឺព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ថ្វាយព្រះរាជកុសល ថ្វាយព្រះរាជសព្ទសាធុការពរបវរមហាប្រសើរ បួងសួងដល់គុណបុណ្យ ព្រះរតនត្រ័យ វត្ថុសក្តិសិទ្ធិ ជួយអភិបាលរក្សា **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** សូមព្រះអង្គមានព្រះជន្មាយុយឺនយូរ មានព្រះរាជសុខុមាលភាពល្អបរិបូណ៌ ដើម្បីបានគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ និងក្តីសុខក្សេមក្សាន្តរបស់មាតុភូមិ និងប្រជារាស្ត្រកម្ពុជា។

ថ្ងៃទី ៣១ ខែ តុលា ឆ្នាំនេះ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់ ព្រះអង្គមានព្រះជន្មគម្រប់ ៨៩ យាងចូល ៩០ព្រះវស្សា ដែលសភាទាំងពីរ រាជរដ្ឋាភិបាល ស្ថាប័នជាតិនានា និងប្រជាពលរដ្ឋក្នុងទូទាំងប្រទេស មានអំណរសាទរប្រារព្ធពិធីបុណ្យចម្រើនព្រះជន្ម ថ្វាយព្រះអង្គ ចាត់ទុកថាជាមហាមង្គលមួយដ៏ពិសេស ដែលក្នុងពង្សាវតាខ្មែរពុំមានអតិត **ព្រះមហាក្សត្រ** អង្គណាមានព្រះជន្មវែងយឺនយូរដូចព្រះអង្គឡើយ។ ទូលព្រះបង្គំ ជាកូន ជាចៅ ចៅទួតរបស់ ព្រះអង្គក្នុងទូទាំងប្រទេស រួមទាំងបងប្អូនខ្មែរនៅក្រៅប្រទេសផង រីករាយណាស់ អបអរសាទរណាស់ ដោយមាន **ព្រះវររាជ បិតាជាតិខ្មែរ** គង់ប្រថាប់ជាម្លប់ប្រកប ដោយទសពិតរាជធម៌កម្ររកបាន នៅក្នុងប្រវត្តិសាស្ត្រ ។

***ព្រះករុណាថ្លៃវិសេស, សម្តេចព្រះមហាក្សត្រី ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់***

***សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជនរួមជាតិ ជាទីគោរពស្នេហា***

សូមទ្រង់ព្រះមេត្តាប្រោសព្រះបរមរាជានុញ្ញាត និងអនុញ្ញាតឱ្យទូលព្រះបង្គំ ខ្ញុំ រំលឹកដោយសង្ខេបនូវព្រឹត្តិការណ៍ ជាប្រវត្តិសាស្ត្រ ដែលព្រះរាជាណាចក្រកម្ពុជា បានឆ្លងកាត់ជាច្រើនទសវត្សរហូតមកដល់បច្ចុប្បន្ននេះ ។

ក្រោយពេលដែលរបបប្រល័យពូជសាសន៍ ត្រូវបានរលំរលាយទៅ នាថ្ងៃ ៧ មករា ១៩៧៩ ផលវិបាកនៃសង្គ្រាមបានបន្សល់ទុកនូវស្លាកស្នាមរបួសខ្ទេចខ្ទាំយ៉ាងធ្ងន់ធ្ងរលើគ្រប់វិស័យ ។ ទន្ទឹមនឹងការស្តារ ការកសាងឡើងវិញនូវអ្វីៗដែលត្រូវខ្ទេចខ្ទាំ បែកបាក់ ប្រេះស្រាំ ការការពារមិនឱ្យរបបប្រល័យពូជសាសន៍កើតឡើងវិញជាលើកទី២ គឺជាភារកិច្ចដ៏ធ្ងន់ធ្ងរ ដែលគណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាលរដ្ឋកម្ពុជា ត្រូវប្រឈមមុខដោះស្រាយ និងទប់ស្កាត់គ្រប់រូបភាព ។

ពេលនោះគណបក្សប្រជាជនកម្ពុជា និងរដ្ឋាភិបាលរដ្ឋកម្ពុជា ក្នុងជំហរដើម្បីបញ្ចប់នូវសង្គ្រាមរ៉ាំរ៉ៃ និងនាំមកនូវសុខសន្តិភាពដ៏ពេញលេញ បានដាក់ចេញគោលនយោបាយបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងចាត់តាំងអនុវត្តដោយខ្ជាប់ខ្ជួន នូវគោលនយោបាយនេះ រហូតឈានដល់ការជួបចរចាជាលើកដំបូងរវាង **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និងទូលព្រះបង្គំ ខ្ញុំ នៅហ្វែរអង់តាដឺន័រ ប្រទេសបារាំង នាថ្ងៃទី ០២ ខែ ធ្នូ ឆ្នាំ ១៩៨៧ ។ ផ្តើមចេញពីជំនួបលើកទី១ នេះ ការអនុវត្តន៍យុទ្ធវិធី ដើម្បីសម្រេចទិសដៅយុទ្ធសាស្ត្រនៃការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ រដ្ឋាភិបាលអតីតរដ្ឋកម្ពុជា បានខិតខំព្យាយាមធ្វើអ្វីៗគ្រប់យ៉ាង ប្រកបដោយជំហរស្មោះត្រង់ រហូតដល់បានសម្រេចនូវកិច្ចព្រមព្រៀងមួយនៅទីក្រុងប៉ារីស នាថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ១៩៩១ ។

កិច្ចព្រមព្រៀងទីក្រុងប៉ារីសមិនបានកំណត់ឲ្យរំលាយអង្គការចាត់តាំងខាង នយោបាយ និង យោធារបស់កម្ពុជាប្រជាធិបតេយ្យ ដែលជាប្រភពនៃរបបប្រល័យពូជសាសន៍ និង សង្គ្រាមនោះឡើយ ផ្ទុយទៅវិញកិច្ចព្រមព្រៀង ទីក្រុងប៉ារីសបានតម្រូវឲ្យភាគីខ្មែរក្រហមជាភាគីស្របច្បាប់នៅកម្ពុជាទៀតផង។

ក្នុងការអនុវត្តន៍កិច្ចព្រមព្រៀងនេះ ហត្ថលេខីនៃភាគីខ្មែរក្រហម បានដកខ្លួនចេញមិនព្រមអនុវត្ត ហើយរកគ្រប់វិធីដើម្បីបំផ្លាញដំណើរការអនុវត្តន៍កិច្ចព្រមព្រៀងក្រុងប៉ារីស ។

ក្នុងស្ថានភាពបែបនេះ រដ្ឋាភិបាលនៃរដ្ឋកម្ពុជាបានខិតខំថែរក្សានូវអាយុជីវិត នៃកិច្ចព្រមព្រៀងនេះ ដោយបានអនុវត្តន៍យ៉ាងម៉ឺងម៉ាត់នូវប្រការទាំងឡាយ ក្នុងកិច្ចព្រមព្រៀងធ្វើសហការយ៉ាងស្មោះត្រង់ជាមួយកម្លាំងនយោបាយនានា និងសហគមន៍អន្តរជាតិ ធ្វើឱ្យមានការបោះឆ្នោតជាសកលនាឆ្នាំ ១៩៩៣ ប្រកបដោយជោគជ័យ និងសុវត្ថិភាព ។

ត្រង់ចំណុចនេះបើសិនជាវាជាការខុសឆ្គងពិតប្រាកដមែន ខ្ញុំសុខចិត្តទទួលខុសត្រូវជួសមុខឲ្យរាជរដ្ឋាភិបាល និង គណបក្សប្រជាជន ព្រោះខ្ញុំជាអ្នក រៀបចំយុទ្ធសាស្ត្រ និង ដឹកនាំអនុវត្តដោយផ្ទាល់នូវនយោបាយឈ្នះៗធ្វើឲ្យខ្មែរក្រហមរលំ រលាយនាំមកនូវសន្តិភាព និង ការបង្រួមបង្រួមជាតិ ឯកភាពទឹកដី ដែលប្រជាពលរដ្ឋទូទាំង ប្រទេសរាប់ទាំងអតីតខ្មែរក្រហម ដែលធ្វើសមាហរណកម្មចូលក្នុងសង្គមជាតិ ហើយទទួលបានផលពីសន្តិភាព ការអភិវឌ្ឍរយៈពេលជាង ១ ទសវត្សកន្លងមកនេះ។ បើសិននេះជាកំហុសមែននោះ គេគួរតែដោះលែងមេដឹកនាំខ្មែរក្រហម ដែលតុលាការកំពុងធ្វើការកាត់ទោសឲ្យចេញមកបង្កើត គណបក្សនយោបាយ និង ចូលរួមបោះឆ្នោតនាពេល មុខវាប្រសើរជាងនាំគ្នានាំគ្នារិៈគន់រាជរដ្ឋាភិបាលថា មិនបានអនុវត្តត្រឹមត្រូវតាមកិច្ចព្រមព្រៀងទីក្រុង

ប៉ារីសនោះ។

ក្រោយការបោះឆ្នោត យើងបានបង្កើតរដ្ឋាភិបាលជាតិជាបណ្ដោះអាសន្នមួយ ដើម្បីទ្រោលសភាពការណ៍ទូទៅក្នុងតំណាក់កាលអន្តរកាល ដែលកើតឡើងតាមរយៈការបោះឆ្នោតនេះ អនុម័តនូវរដ្ឋធម្មនុញ្ញថ្មីនិងបង្កើតរដ្ឋាភិបាលចម្រុះសម្រាប់គ្រប់គ្រងដឹកនាំប្រទេស។ របបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញត្រូវបានស្តារឡើងវិញ ធ្វើឱ្យមាតុភូមិកម្ពុជា បានឈានចូលក្នុងរបត់នៃប្រវត្តិសាស្រ្តមួយថ្មី គឺសន្តិភាព ការបង្រួបបង្រួមជាតិ ប្រជាធិបតេយ្យ សេរីពហុបក្ស និងមានការអភិវឌ្ឍន៍ ។

ជាបន្តបន្ទាប់ព្រះរាជាណាចក្រកម្ពុជា បានបោះជំហានទៅមុខក្នុងស្ថានភាពដែលកត្តាខាងក្នុង និងកត្តាខាងក្រៅ មានភាពអនុគ្រោះយ៉ាងច្រើនធ្វើឱ្យការកសាងសង្គមជាតិ មានការប្រែប្រួល រីកចម្រើនថ្មីគួរឱ្យមានមោទនភាព។ យើងបានរួមគ្នាខិតខំប្រឹងប្រែង ក្រោមបាវចនា **ជាតិ សាសនា ព្រះមហាក្សត្រ** ដើម្បីថែរក្សាការពាររដ្ឋធម្មនុញ្ញ ពង្រឹងសន្តិភាព ស្ថេរភាពនយោបាយ ការបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ និងអភិវឌ្ឍន៍ប្រទេសជាតិ ដោយទទួលបានការគាំទ្រយ៉ាងទូលំទូលាយ ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេស ។

តាមរយៈការអនុវត្តគោលនយោបាយបង្រួបបង្រួមជាតិ ការអនុវត្តគោលនយោបាយឈ្នះឈ្នះ និងគោលនយោបាយយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា យើងទទួលនិងពង្រីកបាននូវការគាំទ្រ ជាបន្តបន្ទាប់ដែលជាកត្តាសំខាន់ចាំបាច់ នៃជ័យជំនះរបស់យើង នៅក្នុងចលនាតស៊ូសង្គ្រោះជាតិ ការពារការរស់ឡើងវិញ របស់ប្រជាជនការពារឯករាជ្យ អធិបតេយ្យជាតិ ស្តារនិងអភិវឌ្ឍន៍ប្រទេស និងក្នុងការដោះស្រាយបញ្ហាកម្ពុជា តាមមាគ៌ានយោបាយឈ្នះឈ្នះដែលលទ្ធផលនេះ បានធ្វើឱ្យកម្ពុជាទទួលបានការគាំទ្រកាន់តែច្រើន ពីសហគមន៍អន្តរជាតិ ។

សមិទ្ធផលទាំងនេះ គឺផ្ដើមចេញពីកម្លាំងសាមគ្គីដ៏ស្វិតស្វាញរបស់ប្រជាជាតិយើង ដែលមានតម្លៃដ៏ជ្រាលជ្រៅជាប្រវត្តិសាស្រ្ត ដោយបានបង្កើតជាមូលដ្ឋានគ្រឹះរឹងមាំនៅលើគ្រប់វិស័យ ដើម្បីធានាដល់ការស្ថិតស្ថេរគង់វង្ស និងរីកចម្រើនរបស់កម្ពុជា ក្រោមព្រះរាជតម្រិះផ្ដួចផ្ដើមដ៏ឈ្លាសវៃនៃការបង្កើតគោលនយោបាយបង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ នៃ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្ដីថ្លៃថ្នូរ និងសុភមង្គល** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ។

- ***ព្រះករុណាព្រះមហាក្សត្រ, ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យជាតិខ្មែរ, សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់***
- **សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា អស់លោក លោកស្រី ជនរួមជាតិ ជាទីគោរពស្នេហា**

កន្លងមកក៏ដូចបច្ចុប្បន្ន និងទៅអនាគត រាជរដ្ឋាភិបាល បានយកអស់ពីកម្លាំងកាយចិត្ត អនុវត្តយ៉ាងសកម្ម នូវយុទ្ធសាស្រ្តចតុកោណតំណាក់កាលទី១ តំណាក់កាលទី២ ដើម្បីកសាងសង្គមកម្ពុជាមួយ លើមាគ៌ាអភិវឌ្ឍន៍គ្រប់វិស័យ។ ភារកិច្ចរួមជាយុទ្ធសាស្រ្តនោះគឺ រួបរួមសាមគ្គីប្រជាជនទាំងមូល ការពាររបបរាជានិយម ការពាររដ្ឋធម្មនុញ្ញ, ការពារព្រះរាជាណាចក្រ

កម្ពុជាឱ្យបានរឹងមាំ ការពារសន្តិភាពដ៏ពេញលេញ ការពារស្ថេរភាពនយោបាយ និងការបង្រួបបង្រួមជាតិ ទប់ស្កាត់គ្រប់សកម្មភាព ដែលធ្វើឱ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ទន្ទឹមនេះ នៅមានការការពារលទ្ធិប្រជាធិបតេយ្យ សិទ្ធិមនុស្ស ការកសាងនីតិរដ្ឋ និងយុត្តិធម៌សង្គម។ ការប្តេជ្ញាខិតខំធ្វើឱ្យមានការរីកចម្រើនថ្មី នូវជីវភាពរស់នៅរបស់ប្រជាជន។ ការជ្រោងខ្ពស់ទង់ឯករាជ្យ អធិបតេយ្យជាតិ ពង្រីកសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិ ដោយខិតខំទាក់ទាញជំនួយបរទេស ដើម្បីអភិវឌ្ឍន៍ប្រទេសជាតិ។

ទូលព្រះបង្គំជាខ្ញុំ ជឿជាក់ថា ក្រោមព្រះបញ្ញាញាណដ៏ភ្លឺថ្លាប្រកបដោយព្រះមហាករុណាទិគុណ និងព្រហ្មវិហារធម៌ធំធេងរបស់ **ព្រះករុណាព្រះមហាក្សត្រ, ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់ មាតុភូមិកម្ពុជានឹងធានាបានសុខសន្តិភាព ស្ថេរភាពនយោបាយ និងសាមគ្គីភាព ឯកភាពជាតិ ក្នុងមហាគ្រួសារដ៏រឹងមាំ ដើម្បីរួមគ្នាកសាងការពារមាតុភូមិអង្គរជាទីស្នេហា រីកចម្រើនប្រកបដោយកិត្តិយសយ៉ាងពិតប្រាកដ។

ពិតមែន ឆ្នាំនេះគ្រោះធម្មជាតិ ទឹកជំនន់បានបង្កឱ្យមានផលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋយើង និងដល់សមិទ្ធផលមួយចំនួន នៅតាមខេត្តជាច្រើនក៏ដោយ ក៏រាជរដ្ឋាភិបាល បានប្រមូលផ្តុំនូវកម្លាំងសរុប មធ្យោបាយសរុបក្នុងជំហានប្រយុទ្ធយ៉ាងស្រួចស្រាល់ ដើម្បីប្រយោមដោះស្រាយនូវផលប៉ះពាល់ទាំងនេះ ដើម្បីស្តារ និងកសាងឡើងវិញ តាមផែនការដែលបានកំណត់ ។

ក្នុងឱកាសដ៏វិសេសវិសាលជាប្រវត្តិសាស្ត្រនេះ ទូលព្រះបង្គំ ខ្ញុំ សូមថ្វាយព្រះរាជសព្ទសាធុការពរ បវរមហាប្រសើរថ្វាយ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ខួបលើកទី៧ នៃការគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះអង្គ សូមព្រះអង្គគង់ប្រថាប់នៅជាម្លប់ដ៏ត្រជាក់ ប្រកបដោយព្រះបរមសុខក្សេមក្សាន្ត មានព្រះជន្មាយុយឺនយូរ ព្រះបញ្ញាញាណភ្លឺថ្លា ដើម្បីបានដឹកនាំមាតុភូមិកម្ពុជារីកចម្រើន តរៀងទៅ។

សូមបួងសួងដល់គុណបុណ្យព្រះរតនត្រ័យ កែវទាំងបី វត្ថុសក្តិសិទ្ធិក្នុងលោក ទេវតារក្សាព្រះរាជាណាចក្រកម្ពុជា ពិសេស ទេវតារក្សាព្រះមហាស្វេតច្ឆត្រ បារមីព្រះកែវមរកត សូមជួយអភិបាលរក្សាប្រទានសព្ទសាធុការពរ ថ្វាយ **ព្រះករុណាព្រះមហាវីរក្សត្រ ព្រះវររាជបិតាជាតិខ្មែរ** និង **សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** សូមទ្រង់ប្រកបដោយព្រះជន្មាយុយឺនយូរជាងរយព្រះវស្សា ព្រះសុខុមាលភាពល្អបរិបូណ៌ ព្រះកាយពលមាំមួន ដើម្បីបានគង់នៅជាម្លប់ដ៏ត្រជាក់ក្សេមក្សាន្ត នៃកូនចៅ ចៅទួត របស់ព្រះអង្គយូរអង្វែង តរៀងទៅ។

សូមថ្វាយ និងជូនពរបវរប្រសើរ សម្តេច ព្រះអង្គម្ចាស់ ព្រះអង្គម្ចាស់ក្សត្រី ទ្រង់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ជនរួមជាតិទាំងអស់ សូមបានប្រកបដោយពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ ជានិច្ចនិរន្តរ៍ តរៀងទៅ ។

*សូមអរព្រះគុណ សូមអរគុណ!*